# លក្ខន្តិកៈក្រុមហ៊ុន

## ARTICLES OF INCORPORATION

# ឃួន ធួរ & សឺវីស

## KHUON TOUR & SERVICE Co., Ltd.

បានប្រថាប់ត្រា

លេខអត្តសញ្ញាណកម្មសារពើពន្ធ: ..[illegible]..

លេខរៀង ១២០ ....ឈ្មោះកម្មសិទ្ធិករ [illegible]

បានបង់ពន្ធប្រថាប់ត្រាចំនួន [illegible],០០..........

អក្សរ [illegible]

តាមបង្កាន់ដៃលេខ [illegible] ចុះថ្ងៃទី [illegible] 2015

រាជធានីភ្នំពេញ ថ្ងៃទី 02 .... ខែ [illegible] .... ឆ្នាំ 2015

ប្រធានសាខាពន្ធដារខណ្ឌមានជ័យ

ម៉េង-ឆុង

**សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត**

SINGLE MEMBER PRIVATE LIMITED COMPANY

**ដើមទុន ៖ ៣,៦០០.០០០.០០០ រៀល**

(=900,000 USD; អត្រា ៤០០០ រៀល /$)

# លក្ខន្តិកៈ
# ក្រុមហ៊ុន

# ឃួន ធួរ & សឺវីស

# KHUON TOUR & SERVICE Co., Ltd.

**សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត**

**ដើមទុន ៖ ៣.៦០០.០០០.០០០ រៀល**

SINGLE MEMBER PRIVATE LIMITED COMPANY

CAPITAL : 3,600,000,000 Riels

## ជំពូក ១

## ទ្រង់ទ្រាយ-កម្មវត្ថុ-នាមករណ៍-ទីស្នាក់ការ-ថិរវេលា

ក្រសួងពាណិជ្ជកម្ម
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
ពណ.ចបព
ចំណុះលេខ 2016/08 ម៉ោង 14H05
ថ្ងៃទី 13-11-15
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

### ប្រការ ១ ៖ ទ្រង់ទ្រាយ

ក្រុមហ៊ុនពាណិជ្ជកម្មមួយបានបង្កើតដោយ ៖

លោក **សុខ សាន្តនិរន្តរ៍** SOK SANNNIRHONN — ពាណិជ្ជករ សញ្ជាតិ ខ្មែរ
ទីលំនៅ ៖ ផ្លូវទន្លេសាប ក្រុម១០ ភូមិព្រែកតាសេក
សង្កាត់ព្រែកតាសេក ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។
អត្តសញ្ញាណបណ្ណលេខ៖ 010743462 ចុះថ្ងៃទី 16-08-2010

ម្នាក់ឯងជាម្ចាស់ ដែលមានទ្រង់ទ្រាយជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតដូចមានដើមទុននិងភាគហ៊ុនខាងក្រោម ។

ចាប់ពីថ្ងៃបានចុះក្នុងបញ្ជីពាណិជ្ជកម្មមក សហគ្រាសនេះមាននីតិបុគ្គលិកលក្ខណៈ និង ជានីតិបុគ្គលមានសិទ្ធិ មានឈ្មោះ មានអាសយដ្ឋាន មានទ្រព្យសម្បត្តិផ្ទាល់របស់សហគ្រាស និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ច្បាប់ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងក្រោមការកំណត់នៃប្រការទាំងឡាយ ដែលមានចែងក្នុងលក្ខន្តិកៈរបស់សហគ្រាស ។

## ប្រការ ២ ៖ កម្មវត្ថុអាជីវកម្ម

សហគ្រាសមានសកម្មភាពដូចតទៅ ៖

-ទេសចរណ៍ ៖ សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត -ទីភ្នាក់ងារទេសចរណ៍ លក់សំបុត្ររថយន្ត កប៉ាល់ និងយន្តហោះ

-ពាណិជ្ជកម្ម ៖ ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ

-នាំចូល ឱសថ សម្ភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសម្ភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ កែច្នៃ ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម-តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន ៖ ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស-សេវាបញ្ជូននិងចែកចាយទំនិញ

-សេវាយកកម្រៃជើងសាលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់-ស្ថាបត្យកម្ម រចនាប្លង់ ត្រួតពិនិត្យនិងសិក្សា គម្រោងប្លង់សំណង់គ្រប់ប្រភេទ

-វិនិយោគលើវិស័យកសិកម្ម ៖ ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម ៖ រោងចក្រ សិប្បកម្ម

ការចូលរួមតាមគ្រប់មធ្យោបាយរបស់សហគ្រាសជាមួយរាល់សហគ្រាស ឬ ក្រុមហ៊ុនដទៃដែលមានហើយ ឬ ដែលនឹងបង្កើត និងដែលមានជាប់ទាក់ទងដោយចំពោះ ឬ មិនចំពោះដល់កម្មវត្ថុអាជីវកម្ម ពិសេសតាមវិធីបង្កើតក្រុមហ៊ុនថ្មី ភាគទុន ការចុះឈ្មោះ ឬ ទិញសិទ្ធិសមាជិក ការរំលាយបញ្ចូលគ្នា សម្ព័ន្ធភាព ឬការចូលរួមសហប្រតិបត្តិការនានា ។

ជាទូទៅ សហគ្រាសធ្វើរាល់ប្រតិបត្តិការពាណិជ្ជកម្មដែលជាប់ទាក់ទងដោយចំពោះ ឬ មិនចំពោះ ឬ ប្រហាក់ប្រហែលគ្នា ឬ ប្រទាក់គ្នា នឹងសកម្មភាពខាងលើ ក្នុងគោលដៅធ្វើឱ្យសហគ្រាសមានការរីកចម្រើន ។

## ប្រការ ៣ ៖ នាមករណ៍

សហគ្រាសធ្វើសកម្មភាពក្រោមនាមថា ៖

# ឃួន ធួរ & សឺវីស

# KHUON TOUR & SERVICE Co., Ltd.

**សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត**

SINGLE MEMBER PRIVATE LIMITED COMPANY

សហគ្រាសមានត្រាសម្គាល់សម្រាប់សហគ្រាសប្រើប្រាស់ ដែលមាននាមករណ៍របស់សហគ្រាសនៅក្នុងផ្ទៃត្រា ។ នៅក្នុងរាល់លិខិតស្នាម វិក្កយបត្រ ឯកសារផ្សព្វផ្សាយ និងឯកសារផ្សេងៗទៀតគ្រប់ប្រភេទ ដែលផ្សាយចេញពីសហគ្រាស ត្រូវតែមានថែងពីក្រោយ ឬ ពីក្រោមនាមករណ៍នូវពាក្យថា ៖ " សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត (SINGLE MEMBER PRIVATE LIMITED COMPANY) " ។

## ប្រការ ៤ ៖ ទីស្នាក់ការ

ទីស្នាក់ការតាំងនៅ ៖ លេខ ២៦៣ ផ្លូវជាតិលេខ ១ ភូមិព្រែកជាងព្រំ សង្កាត់វាលស្បូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

ទីស្នាក់ការនេះ អាចផ្ទេរទៅទីកន្លែងផ្សេងទៀតបានតាមសេចក្តីសម្រេចរបស់ម្ចាស់ សហគ្រាស ។

## ប្រការ ៥ ៖ ថិរវេលា

ចិរវេលារបស់សហគ្រាសត្រូវបានកំណត់ចំនួន ៩៩ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។

# ជំពូក ២

# ដើមទុន-ការផ្ទេរភាគហ៊ុន-ការដឹកនាំសហគ្រាស

## ប្រការ ៦ ៖ ដើមទុន

សមាជិកមានតែម្នាក់ដែលចូលហ៊ុនជាសាច់ប្រាក់សុទ្ធ ៣.៦០០.០០០.០០០ រៀល បែងចែកជា ១.០០០ ភាគហ៊ុន (មួយពាន់ភាគហ៊ុន) ក្នុងមួយភាគហ៊ុនមានតម្លៃ ៣.៦០០.០០០ រៀល ។

លោក **សុខ សាន្តនិរន្តរ៍** ជាម្ចាស់ភាគហ៊ុនទាំងអស់ ដែលមានចំនួន ១.០០០ ភាគហ៊ុន ស្មើនឹងដើមទុន ៣.៦០០.០០០.០០០ រៀល ។

## ប្រការ ៧ ៖ ការបង្កើនដើមទុន-ការបន្ថយដើមទុន

### ក-ការបង្កើនដើមទុន

ដើមទុនសហគ្រាសអាចបានបង្កើនមួយដង ឬច្រើនដងតាមសេចក្តីសម្រេចរបស់ម្ចាស់សហគ្រាស ។

**ខ-ការបន្ថយដើមទុន**

ដើមទុនអាចបន្ថយបាន កុំឱ្យតែក្រោមកម្រិតដែលច្បាប់បញ្ញត្តិ ។

**ប្រការ ៨ ៖ ការផ្ទេរភាគហ៊ុន**

កាលណាម្ចាស់សហគ្រាសទទួលមរណភាព ភាគហ៊ុននៃសហគ្រាសនេះត្រូវបានទៅដល់សហព័ទ្ធនៅរស់ និងអ្នកទទួលមរតក ដែលមានសិទ្ធិបន្តសកម្មភាពសហគ្រាសបន្តទៅទៀត ។ បើមិនដូច្នោះទេ សហព័ទ្ធអាចរំលាយសហគ្រាសនេះ ។ នៅក្នុងករណីនេះ ក្រោយពីបានទូទាត់កាត់សងដល់តតិយជនដែលជាម្ចាស់បំណុលរបស់សហគ្រាសហើយ ភាគហ៊ុនត្រូវបានចែកចាយទៅដល់សហព័ទ្ធនិងអ្នកទទួលមរតក តាមបំណងរបស់ម្ចាស់សហគ្រាស ។

**ប្រការ ៩ ៖ ការដឹកនាំសហគ្រាស**

សហគ្រាសត្រូវដឹកនាំគ្រប់គ្រងដោយម្ចាស់សហគ្រាស ឬដោយនាយកដែលមិនមែនជាម្ចាស់សហគ្រាស ។ នៅក្នុងពេលដែលសហគ្រាសនេះដឹកនាំដោយនាយកដែលមិនមែនជាម្ចាស់សហគ្រាស នាយកនេះទទួលប្រាក់ខែឬប្រាក់រង្វាន់ តាមការសម្រេចនិងព្រមព្រៀងគ្នារវាងម្ចាស់សហគ្រាស និងនាយករូបនេះ ។

សហគ្រាសដឹកនាំដោយ លោក **សុខ សាន្តនិរន្តរី** ម្ចាស់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ។

# ជំពូក ៣

## សេចក្តីសម្រេចរបស់សហគ្រាស-គណនីចរន្ត

**ប្រការ ១០ ៖ សេចក្តីសម្រេចរបស់សហគ្រាស**

សេចក្តីសម្រេចទាំងអស់ជាអំណាចរបស់ម្ចាស់សហគ្រាស ដែលមានការទទួលខុសត្រូវផ្ទាល់ចំពោះតតិយជន ។ ម្ចាស់សហគ្រាសមានអំណាចដកហូតមុខងាររបស់នាយក បើសិនជាមាន នាយកជាតតិយជន ។បើប្រសិនការដកហូតមុខងារនេះ សម្រេចដោយគ្មានមូលហេតុត្រឹមត្រូវ ម្ចាស់សហគ្រាសត្រូវសងជំងឺចិត្តដល់នាយក ។ ប៉ុន្តែនាយកនេះមិនអាចអនុញ្ញាតឱ្យចូលកាន់តំណែងដើមវិញបានទេ ។

**ប្រការ ១១ ៖ គណនីចរន្ត**

បើសិនជាមានការចាំបាច់ ម្ចាស់សហគ្រាស អាចទុកប្រាក់នៅក្នុងគណនីចរន្តរបស់ សហគ្រាស ។ ការប្រាក់នៅក្នុងគណនីចរន្តនេះ ត្រូវសមស្របទៅតាមការប្រាក់ដែលអនុញ្ញាតតាម ច្បាប់ ។ ហាមផ្តាច់មិនឱ្យម្ចាស់សហគ្រាសខ្ចីប្រាក់សហគ្រាសឡើយ ។

# ជំពូក ៤

## ឆ្នាំការិយបរិច្ឆេទ-ប្រាក់ចំណេញឬខាត-ការរំលាយ-ការផ្លាស់ប្តូរទ្រង់ទ្រាយ

**ប្រការ ១២ ៖ ឆ្នាំការិយបរិច្ឆេទ**

ឆ្នាំការិយបរិច្ឆេទ ចាប់ផ្តើមពីថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ លើកលែងតែឆ្នាំការិយបរិច្ឆេទដំបូង ដែលត្រូវចាប់ផ្តើមពីថ្ងៃចុះបញ្ជីពាណិជ្ជកម្ម និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំ បង្កើតសហគ្រាស ។

## ប្រការ ១៣ ៖ ការប្រកាសលទ្ធផលនៃសហគ្រាស

រៀងរាល់ឆ្នាំក្រោយការបិទការិយបរិច្ឆេទ សហគ្រាសត្រូវចាត់ចែងធ្វើគណនេយ្យលទ្ធផល និងតារាងតុល្យការ ។ គណនេយ្យលទ្ធផល មានរាប់ចំណូលនិងចំណាយ ហើយបង្ហាញសំណល់ជាប្រាក់ចំណេញ ឬ ប្រាក់ខាតរបស់សហគ្រាស ។ នៅលើប្រាក់ចំណេញ ត្រូវមានការដកហូត ៥% យ៉ាងតិច ដើម្បីបង្កើតជាមូលនិធិបម្រុង ។ ការដកហូតយកភាគនៃប្រាក់ចំណេញនេះត្រូវបញ្ចប់កាលបើមូលនិធិបម្រុងនេះបានគ្រប់ចំនួន ១០% នៃដើមទុនរបស់សហគ្រាស ។

## ប្រការ ១៤ ៖ ការខាតលើសពីពាក់កណ្តាលនៃដើមទុនដំបូង

បើសិនជាឯកសារគណនេយ្យ បង្ហាញឱ្យឃើញការខាតរបស់សហគ្រាសរហូតដល់កម្រិតលើសពីពាក់កណ្តាលដើមទុនដំបូង ម្ចាស់សហគ្រាសត្រូវតែរំលាយសហគ្រាសមុនថិរវេលាកំណត់ ។

ការរំលាយនេះត្រូវធ្វើឡើង បើប្រសិនណាស្ថានការណ៍មិនអាចធ្វើឱ្យមានប្រក្រតីភាពឡើងវិញបានទេ ក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីបានពិនិត្យឃើញនូវការខាតនេះ ។

## ប្រការ ១៥ ៖ ការរំលាយ និងជម្រះបញ្ជីសហគ្រាស

កាលណាផុតថិរវេលារបស់សហគ្រាស ឬក្នុងករណីមរណភាព ការបាត់បង់សមត្ថភាព ការសម្រេចរបស់តុលាការលើទុព្វលភាពផ្ទាល់របស់ម្ចាស់សហគ្រាស ឬការខាតបង់ដើមទុនលើសពីពាក់កណ្តាល សហគ្រាសត្រូវធ្វើការជម្រះបញ្ជីនិងរំលាយសហគ្រាស ។ សេចក្តីសម្រេចស្តីពីការរំលាយសហគ្រាស ត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ការរំលាយសហគ្រាស ។ សហគ្រាសត្រូវបញ្ឈប់អត្ថិភាពរបស់ខ្លួន ចាប់ពីថ្ងៃដែលមានចុះនៅក្នុងវិញ្ញាបនបត្របញ្ជាក់ការរំលាយសហគ្រាសនេះ ។

## ប្រការ ១៦ ៖ ការផ្លាស់ប្តូរទ្រង់ទ្រាយ

សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត អាចផ្លាស់ប្តូរទ្រង់ទ្រាយទៅជាក្រុមហ៊ុន ឯកជនទទួលខុសត្រូវមានកម្រិតបានកាលបើមានរូបវន្តបុគ្គលឬនីតិបុគ្គលមួយ ឬច្រើនទទួលការ យល់ព្រមពីម្ចាស់សហគ្រាសឱ្យចូលជាសមាជិក ។

## ប្រការ ១៧ ៖ សោហ៊ុយចំណាយ

ចំណាយក្នុងការបង្កើតសហគ្រាសនេះ ត្រូវបញ្ចូលក្នុងបញ្ជីចំណាយរបស់សហគ្រាស ។

ធ្វើជា ច្បាប់ដើម ថ្ងៃទី 13 ខែ 11 ឆ្នាំ ២០១៥

ក្រសួងពាណិជ្ជកម្ម
នាយកដ្ឋានចុះបញ្ជី ពាណិជ្ជកម្ម
តំកល់ទុកលេខ: 3016/08 ពណ.ចបព
ថ្ងៃទី 13.11.15 ម៉ោង 14h15
មន្ត្រីនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

**សុខ សាន្តនិរន្តរ៍**

# MEMORANDUM AND ARTICLES OF ASSOCIATION

# KHUON TOUR & SERVICE Co., Ltd.

SINGLE MEMBER PRIVATE LIMITED COMPANY

**Capital : 3.600.000.000 Riels**

(=900.000 USD –Rate : 4000 Riels/$ )

This document is certified it to be translated for understanding into English from its original Khmer document, if there is any difference found in meaning from the original Khmer version the original English document shall be adopted.

# STATUTE OF

# *KHUON TOUR & SERVICE Co., Ltd.*

SINGLE MEMBER PRIVATE LIMITED COMPANY
Capital : 3.600.000.000 Riels
(=900.000 USD –Rate : 4000 Riels/$ )

## Part I

FORM, BUSINESS OBJECTIVE, NAME, HEAD OFFICE, DURATION

ARTICLE 1 :

Form of the company

A business firm is created by:

- **Mr. SOK SANNNIRHONN** Profession : Businessman
  Nationality : CAMBODIAN
  Address : Tonlesap St. Group 10, Preak Tasek Village, Preak Tasek Commune, Russeikeov District, Phnom Penh City.
  Passport N° : 010743462 Dated: 16-08-2010

A single owner of the firm and is doing business as a sole proprietorship with limited liability as indicated below by its capital and shares.

Since the date of registration with the Ministry of Commerce, the law considers this company as an artificial person and as a legal entity, which has its own rights, name, address, and assets which are different from the firm's assets. This company shall be governed by the commercial law and shall remain under these articles of sole proprietorship.

ARTICLE 2 :

Business objective

The firm shall perform the following activities:

- Tourism: Hotels, Restaurants, Entertainment Center; Tourist agent, selling all kind of transportation tickets;
- Commercial operation: buying, selling, changing of goods,
  Importing Exporting all kinds of goods,
  Importing all kinds of medicines and medical equipments;
- Buying, selling, leasing and mortgage of commercial funds, land and housings;
- Renting, warehousing of all kinds of products and goods,
  Repairing of equipments and all kinds of goods;

- Currency exchange, inventions, purchase and sales of jewelry;
- Hospital, consulting and treating of diseases;
- School establishment;
- Commercial agent -Commercial representative;
- Financial and commercial consultation services;
- Advertising services;
- Publishing;
- Producing of cinema, Video CD;
- Transportation: sea, land and air transports,
  Goods forwarding and distribution services;
- Transportation commission;
- Construction, Repairing, building, bridge and road;
- Investment in the field of agriculture: Planting, livestock.
- Investment in the field of industry: Factory, Handicraft.

To joint by all means of the company with other or newly set up enterprises or companies which direct or indirectly involved business objective of the company especially by means of establishing a new company, sharing as new member or buying member's rights, creating mixed activities, joint venture or participating in other cooperation's.

In general the firm will operate only the activities that relate or are similar to the above transactions with the only purpose of expanding or improving the firm.

ARTICLE 3 :

Name of the company

The firm shall be conducted under the firm name as:

***KHUON TOUR & SERVICE Co., Ltd.***

which is a Single Member Private Limited Company.

The firm has its seal to indicate its name. All firm's letters, invoices, and other documents shall be written in clear and full words, either in the back or in the front, with the name of the firm and the symbol SINGLE MEMBER PRIVATE LIMITED COMPANY as well as the amount of stated capital.

ARTICLE 4 :

Head office

The firm head office is located at house:

No.263, National Street 1, Phum Prek Tajom, Sangkat Vealsbov, Khan Meanchey, Phnom Penh City.

This head office can be moved to elsewhere according to the decision made by its owner.

ARTICLE 5 :

Duration

The period of duration of the firm's existence shall begin since the date of registration with the Ministry of Commerce and the creation of the firm and shall continue for a term of ninety nine ( 99 ) years hereafter.

## PART II
## CAPITAL - SHARES

ARTICLE 6 :

Capital

There shall be only one (1) shareholder who contributes to the business a capital of 3.600.000.000 Riels( in cash only, which is divided into 1000 shares, each with a par value of 3.600.000 Riels.

**Mr. SOK SANNNIRHONN** is the only owner of these 1000 shares totaling 3.600.000.000 Riles in cash which is deposited at a bank.

ARTICLE 7 :

Increases or Decreases of capital

a/. Increases of capital

The firm's capital may be increased one or more times according to the decisions made the owner.

b/. Decreases of the capital

The firm's capital may be reduced to the minimum extent the law requires.

ARTICLE 8 :

Transfer of shares

When the owner of the firm dies, all shares shall be transferred to all his beneficiaries who are entitled to continue the firm's operations. Otherwise, the beneficiaries may ask to dissolve the firm; in such a case, the shares, after being be divided among the beneficiaries according to the owner's original will.

ARTICLE 9 :

Management of the firm.

The firm shall be managed by its owner or by an auditor who owns no shares. While the firm is managed by an auditor, he/ she is entitled to get paid or receive reward following an agreement made between him/ her and the firm's owner.

The firm shall be managed by: **Mr. SOK SANNNIRHONN**

## Part III
## DECISIONS OF THE FIRM

ARTICLE 10 :

All decisions shall be made by the firm's owner who is held directly responsible to all third parties. The owner is empowered to remove the auditor from his/ her position in the firm if he/ she is a third party. If the auditor is removed unjustifiably, he/ she is not allowed to regain his/ her original position in the firm.

ARTICLE 11 :

Account from which the firm borrows

If necessary the firm's owner may keep money in the firm's current account in which interest rates shall be consistent with the legal rates. The firm's owner shall be prohibited from borrowing (withdrawing) from the firm.

## Part IV
## ACCOUNTING PERIOD AND SHARES OF PROFITS OR LOSSES

ARTICLE 12 :

Accounting Periods and Inventory

All accounting periods shall begin on 1 January and shall terminate on 31 December of the same year. In particular, the firm's original accounting period shall begin on the day of registration with the Ministry of Commerce and shall terminate on 31 December.

ARTICLE 13:

Disclosure of the Firm's Statement of Business

At the end of each calendar year, a full inventory shall be prepared, and a balance sheet and an income statement made. The income statement shall include all revenues and expenses of the firm and shall indicate its net profits or losses.

At least 5% of the firm's profits shall be deducted and kept as reserve; these deducted and kept as reserve; these deductions from the firm's profits shall be stopped if the reserves reach 10% of the firm's original stated capital.

ARTICLE 14:

Losses incurred more than half of the firm's original stated capital

If the accounting records show that the firm has incurred losses more than half of the firm's original stated capital, the owner shall dissolve the firm before the period of duration of the firm's existence matures.

This dissolution shall be made if the situation is not favorable to put the firm back to its regularity within a period of one year after such losses have been examined.

ARTICLE 15:

Dissolution and Liquidation of the Firm

When the period of duration of the firm's existence matures or in case of a dissolution caused by the owner's death or owner's loss of capacity, or a decision made by a court on the owner's proper invalidity, or the firm has incurred a loss amounted to more than half of the firm's original stated capital, the firm shall liquidate its assets. This dissolution will have effects on other people unless a publication is made in the trade register.

ARTICLE 16:

Changing the Firm's Nature

The Sole Proprietorship Company Limited may change its nature into a limited partnership when one or more individuals or legal entities are accepted by the owner to be members of the firm.

ARTICLE 17:

Disputes and Court Jurisdiction

If a dispute arises, the Commercial Court of Phnom Penh has jurisdiction over it.

ARTICLE 18:

Costs Incurred in the Formation of the Firm

All costs incurred in the formation of the firm shall be recorded in the firm's book of expenditure accounts.

Dated: ,2015

Read and approved

Accept the position of Director

**SOK SANNNIRHONN**